- បានឃើញអនុក្រឹត្យលេខ ៨៤/អនក/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សម្រេច**

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** ជូនលោកស្រី **ឌាន គីមច្រ៊ង់** រស់នៅសហរដ្ឋអាមេរិកដែលបានជួយកសាងអាគារសិក្សាមួយខ្នង រួមនឹងសម្ភារៈសិក្សា អណ្តូងទឹក និងបង្គន់អនាម័យ ជូនសាលាបឋមសិក្សាទ្រា ក្នុងឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំណាយអស់ទឹកប្រាក់ចំនួន ២២.០០០ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិង កីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ២–សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៤១ សសរ**

**ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយឈើចំនួន ៣៩១**

**កំណាត់ ស្មើនឹង ១.៥៣៧,៥២៩៥ម$^3$ ដែលស្ថិតនៅខេត្តកណ្តាល**

**បានសំរេចដាក់លក់ឡាយឡុង**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

យោងតាមការងារចាំបាច់

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ដោះស្រាយឈើចំនួន ៣៩១ កំណាត់ ស្មើនឹង ១.៥៣៧,៥២៩ ម៣ ដែលតុលាការខេត្តកណ្តាលបានសំរេចអោយលក់ឡាយឡុង ដែលមានសមាសភាពដូចខាងក្រោម ÷

១-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធាន

២-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៤-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

៥-តំណាងខេត្តកណ្តាល សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

-ចុះពិនិត្យជាក់ស្តែងចំនួនឈើដែលបានរក្សាទុកនៅឃ្លាំងរោងចក្រអារឈើកាសូទីម នៅ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល

-ពិភាក្សាកំណត់ថ្លៃឈើ និង រៀបចំដាក់អោយដេញថ្លៃតាមបែបបទ និង នីតិវិធីជាធរមាន

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារខាងលើជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាលខេត្តកណ្តាល និង ឯកឧត្តមអស់លោក តំណាងក្រសួង និង ខេត្តដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយក
ហត្ថលេខា និងត្រា
**ស ខេង**

★★★